# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

## <u>សេចក្តីប្រកាសពត៌មាន</u>

# ការប្រកាសបើកកម្មវិធីបញ្ចប់អំពើហឹង្សាលើស្ត្រី

នាថ្ងៃនេះ ឯកអគ្គរាជទូតអូស្ត្រាលីលោកជំទាវ **អាលីសុន បើរ៉ូ** និងលោកជំទាវវេជ្ជបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី បានរួមគ្នាប្រកាសបើកសម្ពោធជាផ្លូវការនូវកម្មវិធីបញ្ចប់អំពើហឹង្សាលើស្ត្រី នៅទីស្តីការនៃក្រសួងកិច្ចការនារី ។ ការផ្តល់ជំនួយលើកម្មវិធីនេះ ត្រូវបានប្រកាសកាលពីឆ្នាំ ២០១៣។

លោកជំទាវឯកអគ្គរាជទូត អាលីសុន បើរ៉ូ និងលោកជំទាវវេជ្ជបណ្ឌិត អ៊ឹង កន្ថាផាវី បានចុះហត្ថលេខាលើអនុស្សារណៈស្តីពីការរៀបចំចាត់ចែង នៃកម្មវិធីបញ្ចប់អំពើហឹង្សាលើស្ត្រី។

ក្នុងឆ្នាំ២០១៣ រដ្ឋាភិបាលអូស្ត្រាលីបានប្រកាសផ្តល់មូលនិធិរហូតដល់២៤លានដុល្លាអូស្ត្រាលី ដើម្បីគាំទ្រដល់ការបញ្ចប់អំពើហិង្សាលើស្ត្រីនៅកម្ពុជា ព្រមទាំងធ្វើការផ្លាស់ប្តូរឥរិយាបទនានា និងការបង្ការអំពើហិង្សា ដើម្បីធ្វើអោយស្ត្រីនិងកុមារនៅក្នុងសហគមន៍ទទួលបាននូវសុខសុវត្ថិភាពប្រសើរជាងមុន។ ចាប់តាំងពីពេលនោះ រដ្ឋាភិបាលអូស្ត្រាលីបានជួយជ្រោមជ្រែងដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការកសាងផែនការសកម្មភាពថ្នាក់ជាតិលើកទីពីរដើម្បីបញ្ចប់អំពើហឹង្សាលើស្ត្រី (ហៅកាត់ថា NAPVAW)។ ក្រៅពីនោះ អូស្ត្រាលីបានឧបត្ថម្ភមូលនិធិលើផ្នែកអំពើហឹង្សា នៃការអង្កេតសុខភាពប្រជាសាស្ត្ររបស់កម្ពុជា និងបានរួមវិភាគទានដល់ការសិក្សាថ្នាក់ជាតិលើវិសាលភាពនៃអំពើហឹង្សាលើស្ត្រី។

អូស្ត្រាលីក៏បានផ្តល់ជំនួយដល់អង្គការក្រៅរដ្ឋាភិបាលនានាដូចជា ភ្នាក់ងារសម្រាប់កិច្ចសហប្រតិបត្តិការបច្ចេកទេសនិងការអភិវឌ្ឍន៍ ACTED អង្គការចិត្តសង្គមអន្តរវប្បធម៌ TPO មជ្ឈមណ្ឌលជំនួយផ្នែកច្បាប់កម្ពុជា LAC និងអង្គការ Hagar ដើម្បីផ្តល់សេវាសុខភាពពិគ្រោះចិត្តសាស្ត្រសង្គម ជម្រក ការអប់រំ និងជំនួយផ្លូវច្បាប់សម្រាប់ស្ត្រីនិងកុមារីដែលរង

គ្រោះដោយអំពើហិង្សា។ មកដល់ពេលនេះ មានស្ត្រីនិងកុមារីជាង៥០០នាក់បានទទួលផលពីជំនួយទាំងនេះ។

ក្នុងក្របខ័ណ្ឌអនុស្សារណៈស្តីពីការរៀបចំចាត់ចែង ដែលត្រូវបានចុះហត្ថលេខានាថ្ងៃនេះ កម្មវិធីបញ្ចប់អំពើហឹង្សាលើស្ត្រី នឹងផ្តោតលើគោលដៅសំខាន់ចំនួនបី៖

- សេវាកម្ម៖ សុខភាព សេវាពិគ្រោះចិត្តសាស្ត្រសង្គម ជម្រក ការអប់រំនិងជំនួយផ្លូវច្បាប់ ដើម្បីឆ្លើយតបប្រកបដោយប្រសិទ្ធភាពខ្ពស់ចំពោះរាល់សកម្មភាពហឹង្សាលើស្ត្រីនិងកុមារី។
- ការបង្ការ៖ ធ្វើការជាមួយរដ្ឋាភិបាល សង្គមស៊ីវិល និង វិស័យឯកជនលើឥរិយាបទនានាចំពោះអំពើហិង្សាលើស្ត្រី។
- ការងារយុត្តិធម៌៖ ធ្វើការជាមួយស្ថាប័នច្បាប់និងយុត្តិធម៌ដើម្បីបង្កើនការឆ្លើយតបរបស់កម្លាំងនគបាលនិងតុលាការ។

ថ្លែងក្នុងអង្គពិធីចុះហត្ថលេខា លោកជំទាវ អាលីសុន ប៊ើរ៉ូ បានមានប្រសាសន៍ថា “ថ្ងៃនេះគឺជាការកត់ត្រានូវទំព័រថ្មីមួយទៀត នៃកិច្ចសហប្រតិបត្តិការរវាងប្រទេសអូស្ត្រាលី និងកម្ពុជា... ការចុះហត្ថលេខាលើអនុស្សារណៈនេះតំណាងអោយការប្តេជ្ញាចិត្តរបស់យើង ក្នុងការធ្វើការរួមគ្នាដើម្បីជួយដល់ស្ត្រីនិងកុមារី អោយពួកគាត់រស់រានដោយចៀសផុតអំពីអំពើហិង្សា និងអាចចូលរួមចំណែកយ៉ាងពេញលេញសំរាប់អនាគតកម្ពុជា”។

**ទំនាក់ទំនងពត៌មាន៖ លោក សាយម៉ុន ហ្វៀលឡូវស៍ អនុប្រធានបេសកកម្ម**
**ទូរស័ព្ទលេខ ០២៣ ២១៣ ៤៧០**
**ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៤**